

# មើមឆៃថាវដ៏ធំ

និពន្ធ និងរូបភាពដោយ

សិស្សនៅប្រទេសជប៉ុន



កាលពីព្រេងនាយ មានលោកតាម្នាក់បានដាំឆៃថាវ។គាត់ក៏បាននិយាយ
"កូនឆៃថាវអើយកូនឆៃថាវ ឯងត្រូវតែឆាប់ធំឡើង មានមើមធំនិងមានរសជាតិឆ្ងាញ់"។



កូនឆៃថាវបានលូតលាស់ស្លឹកខៀវស្រងាត់ មើលទៅមានរសជាតិឆ្ងាញ់ ហើយមើមវាពិតជាធំខ្លាំងណាស់។



នៅថ្ងៃមួយ លោកតាក៏បានទៅដកមើមឆៃថាវនោះ។

លោកតាបានខំប្រឹងទាញមើមឆៃថាវនោះម្ដងហើយម្ដងទៀត នៅតែទាញមិនរួច។



លោកតាក៏បានទៅហៅលោកយាយឱ្យមកជួយ។ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។
ពួកគេបានខំប្រឹងទាញមើមឆៃថាវនោះម្តងហើយម្តងទៀត ប៉ុន្តែនៅតែទាញមិនរួច។



ដូច្នេះលោកយាយក៏បានទៅហៅចៅស្រីរបស់គាត់ឱ្យមកជួយ។

ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា ហើយលោកតាទាញមើមឆៃថាវ។



ពួកគេបានទាញមើមឆៃថាវនោះម្តងហើយម្តងទៀត នៅតែមិនរួច។



ចៅស្រីបានទៅហៅកូនក្របីឱ្យមកជួយ។ កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ
លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។



ពួកគេបានទាញមើមឆៃថាវនោះម្តងហើយម្តងទៀត ប៉ុន្តែនៅតែមិនរួច។



កូនក្របីក៏បានទៅហៅកូនស្វាឱ្យមកជួយ។ កូនស្វាទាញកូនក្របី កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។



ពួកគេបានខំប្រឹងទាញស្ពៃថាវនោះម្ដងហើយម្ដងទៀត ប៉ុន្តែនៅតែមិនរួច។



កូនស្វាបានទៅហៅអណ្ដើកឱ្យមកជួយ។ អណ្ដើកទាញកូនស្វា កូនស្វាទាញកូនក្របី កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។



ពួកគេបានខំប្រឹងទាញមើមឆៃថាវនោះម្តងហើយម្តងទៀត...



...ចុងក្រោយ ពួកគេពិតជាធ្វើបានសម្រេចមែន។ ពួកគេដកមើមឆៃថាវនោះបានហើយ!

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែល
មិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូច
ក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យ
ចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើ
សាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ R4C បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្រប
ទៅនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំនិងមានវគ្គបំប៉ន
លោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រ ដើម្បីទទួលបានធនធាន
បង្រៀន៖ https//rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

មូលនិធិផ្តល់ដោយអង្គការTukTukនិងសមាគម
រ៉ូតារីក្លឹប។

សៀវភៅរឿងនេះគូរដោយនិស្សិតនៃសកលវិទ្យាល័យ
**Seinan Jo Gakuin** នៃប្រទេសជប៉ុន ។
ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ
ចំពោះលោកស្រី **Kristen Maree Sullivan** ដែលបាន
សហការជាមួយអង្គការដឹកនាំសម្របសម្រួលនិស្សិត
ស្ម័គ្រចិត្តបុគ្គលិកទាំងអស់នៅក្នុងអង្គការដោយ
ក្តីមេត្តាធម៌ក្នុងការបង្កើតសៀវភៅនេះឡើង។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន